**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទូរគមនាគមន៍កម្ពុជា**
លេខ ០៣២៦ ទ.ក.

# សេចក្តីជូនដំណឹង

## ស្តីពីការប្រមូលមកវិញឯកសណ្ឋានជាងរបស់ទូរគមនាគមន៍កម្ពុជា

**ទូរគមនាគមន៍កម្ពុជា** ( **ទ.ក.** ) សូមធ្វើការប្រមូលយកមកវិញ "**ឯកសណ្ឋានជាង**" ដែលបានចេញសម្រាប់ប្រើប្រាស់ឱ្យក្រុមហ៊ុន ISPs និងអ្នកម៉ៅការបន្ត (Subcontractor) ក្នុងការប្រើប្រាស់ស្ថាបនានិងជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធបណ្តាញឱ្យ ទ.ក.។ សូមក្រុមហ៊ុន ISPs, អ្នកម៉ៅការបន្ត (Subcontractor) និងបុគ្គលិករបស់ខ្លួនត្រូវឈប់ប្រើប្រាស់ស្លៀកពាក់ឯកសណ្ឋានជាងរបស់ ទ.ក. ហើយត្រូវប្រគល់ឯកសណ្ឋានជាងទាំងអស់ជូនមក ទ.ក. វិញជាបន្ទាន់ តាមលក្ខខណ្ឌដូចតទៅ៖

- **បញ្ឈប់ការប្រើប្រាស់ភ្លាមៗ៖** មិនត្រូវពាក់ ឬប្រើប្រាស់ឯកសណ្ឋានជាងរបស់ ទ.ក. ណាមួយឡើយសម្រាប់គ្រប់សកម្មភាពរបស់ខ្លួនដោយគ្មានការអនុញ្ញាតពី ទ.ក.។
- **ប្រគល់ឯកសណ្ឋានទាំងអស់៖** ប្រគល់ឯកសណ្ឋានជាងទាំងអស់ដែលខ្លួនមាន ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងមិនឱ្យហួស ១សប្តាហ៍ ចាប់ពីទទួលបានការជូនដំណឹងនេះ។
- **រាយការណ៍អំពីឯកសណ្ឋានបាត់៖** ករណីឯកសណ្ឋានដែលបាត់ ឬមិនបានប្រគល់មកវិញ ត្រូវតែរាយការណ៍ជាលាយលក្ខណ៍អក្សរមក ទ.ក. ។
- ក្រុមហ៊ុន ISPs, អ្នកម៉ៅការបន្ត និងបុគ្គលិកណាមួយដែលត្រូវបានរកឃើញថាកំពុងប្រើប្រាស់ឯកសណ្ឋាន ទ.ក. ដោយគ្មានការអនុញ្ញាតនឹងត្រូវទទួលខុសត្រូវ និងត្រូវប្រឈមមុខផ្លូវច្បាប់។

អាស្រ័យហេតុដូចបានជូនដំណឹងខាងលើ សូមបណ្តាក្រុមហ៊ុន ISPs, អ្នកម៉ៅការបន្ត (Subcontractor) ធ្វើការសហការដោយភាពទទួលខុសត្រូវខ្ពស់។

ថ្ងៃសុក្រ ១ កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០២៦

Telecom Cambodia

សម្រាប់ការសម្របសម្រួលលើដំណើរការប្រគល់មកវិញសូមទាក់ទង៖

- លោក រស់ សុខា ០១៧ ៧៨៨ ៦៩០
- លោក ហ៊ិន ប្រុស ០១២ ៨៧ ៣១២១